ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លេខ :......០៦៤..........អ.ជ.ប.ជ.អ

ភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០០៩

# សេចក្តីសម្រេច

## ស្តីពី

## ការកែសំរួលក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស ប្រចាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

---

## ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រតក ០១០០-០០៧ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រិត្យលេខ ១០៩ អនក្រ បក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងគំរោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយពហុវិសយ័ដើម្បីឆ្លើយតបទៅនឹងការរីករាលដាល នៃមេរោគអេដស៍/ជំងឺអេដស៍ ២០០៦-២០១០
- យោងសេចក្តីសំរេចរបស់អង្គប្រជុំក្រុមការងារ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០០៨

## សម្រេច

ប្រការ ១: កែសំរួលក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរសប្រចាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | | ប្រធាន |
| ២- លោកវេជ្ជ. លី ពេញស៊ុន អនុមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | | អនុប្រធាន |
| ៣- តំណាងអ្នកទទួលបន្ទុកការងារ MSM ( អ.ជ.ប.ជ.អ ) | | សមាជិក |
| ៤- តំណាង | ក្រសួងការពារជាតិ | សមាជិក |
| ៥- តំណាង | ក្រសួងមហាផ្ទៃ | សមាជិក |
| ៦- តំណាង | ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧- តំណាង | ក្រសួងធម្មការ និងសាសនា | សមាជិក |
| ៨- តំណាង | ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- តំណាង | ក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ | សមាជិក |
| ១០- តំណាង | អង្គការ UNAIDS | សមាជិក |
| ១១-តំណាង | អង្គការ UNESCO | សមាជិក |
| ១២-តំណាង | អង្គការ សុខភាពគ្រួសារអន្តរជាតិ (FHI) | សមាជិក |
| ១៣-តំណាង | អង្គការ KHANA | សមាជិក |
| ១៤-តំណាង | អង្គការ ឃែរ ( CARE ) | សមាជិក |
| ១៥-តំណាង | អង្គការ PSI | សមាជិក |
| ១៦-តំណាង | អង្គការ ម៉ារីស្តូបអន្តរជាតិកម្ពុជា ( MSIC ) | សមាជិក |
| ១៧-តំណាង | អង្គការ PSF | សមាជិក |
| ១៨-តំណាង | អង្គការ BBC WST | សមាជិក |
| ១៩-តំណាង | អង្គការ PACT Cambodia | សមាជិក |
| ២០- តំណាង | Freeland Consultant (Mr. Michal P.De Guzman) | សមាជិក |
| ២១-តំណាង | អង្គការ រ៉ាក់ (RHAC ) | សមាជិក |
| ២២-តំណាង | បណ្តាញចតុមុខ (National MSM Network ) | សមាជិក |
| ២៣-តំណាង | អង្គការ MHC | សមាជិក |
| ២៤-តំណាង | អង្គការ MHSS | សមាជិក |

| | | |
|---|---|---|
| ២៥-តំណាង | អង្គការ KHEMERA | សមាជិក |
| ២៦-តំណាង | អង្គការ CSSD | សមាជិក |
| ២៧-តំណាង | អង្គការ CUD | សមាជិក |
| ២៨-តំណាង | អង្គការ KDFO | សមាជិក |
| ២៩-តំណាង | អង្គការ KAHNHNA | សមាជិក |

ប្រការ ២: ក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរសមានតួនាទី និងភារៈកិច្ចដូចខាងក្រោម:

- ស្វែងរកការគាំទ្រផ្នែកគោលនយោបាយ យុទ្ធសាស្រ្ត និងការអនុវត្តន៍ទាក់ទងនឹងក្រុមបុរសស្រឡាញ់បុរស និងមេរោគអេដស៍ និងជំងឺអេដស៍។
- រៀបចំ ពិនិត្យឡើងវិញ កែសំរួល និងផ្តល់យោបល់គោលនយោបាយ គោលការណ៍ណែនាំ សេចក្តីប្រកាស និងសារាចរណែនាំ ដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស។
- រៀបចំ ពិនិត្យឡើងវិញ និងកែសំរួលផែនការយុទ្ធសាស្រ្តសំរាប់រយៈពេលវែង រយៈពេលខ្លី និងផែនការប្រតិបត្តិរបស់ក្រុមការងារបុរសស្រឡាញ់បុរស។
- រៀបចំឧបករណ៍សំរាប់អន្តរាគមន៍ និងលើកកំពស់សមត្ថភាពបច្ចេកទេស និងសមត្ថភាពស្ថាប័នដល់សមាជិកក្រុមការងារដើម្បីរួមចំណែកអនុវត្តផែនការប្រតិបត្តិសំរាប់ក្រុមបុរសស្រឡាញ់បុរស។
- វិភាគស្ថាភាព និងការឆ្លើយតបដែលទាក់ទងនឹងការទទួលបានព័ត៌មាន និងសេវា ដែលទាក់ទងនឹងមេរោគអេដស៍និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស។ ហើយទិន្នន័យដែលប្រមូលបានយកមកប្រើប្រាស់ដើម្បីកំណត់អាទិភាពអន្តរាគមន៍ទៅលើក្រុមប្រជាជនដែលប្រឈមមុខខ្ពស់ និងទីតាំងភូមិសាស្រ្តដែលត្រូវធ្វើអន្តរាគមន៍។
- សហការជាមួយនឹងក្រុមការងារបច្ចេកទេសដ៏ទៃទៀតដើម្បីរួមចំណែកធ្វើអោយសំរេចបាននូវគោលដៅសូចនាកររបស់ផែនការយុទ្ធសាស្រ្តជាតិលើកទី II ( NSP II ) គោលដៅទទួលបានជាសាកល ( UA ) និងរបាយការណ៍ ស្តីពីបញ្ហាអេដស៍ ( UNGASS ) ដែលទាក់ទងនឹងក្រុមបុរសស្រឡាញ់បុរស។
- សំរបសំរួលជាមួយស្ថាប័នពាក់ព័ន្ធពិសេសសមាជិកក្រុមការងារដើម្បីអនុវត្តនូវគោលនយោបាយ ផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិ ដែលទាក់ទងនឹងក្រុមបុរសស្រឡាញ់បុរស។
- សហការជាមួយប្រទេសជិខាង និងក្នុងតំបន់ដើម្បីចែករំលែកនូវបទពិសោធន៍ដែលទាក់ទងនឹងមេរោគអេដស៍និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស។

- ចលនាប្រភពធនធានដើម្បីពង្រីកអន្តរាគមន៍ និងបង្កើនគុណភាពសេវា ដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស ។
- សំរបសំរួលក្នុងការប្រមូលទិន្នន័យវិភាគ និងផ្សព្វផ្សាយទិន្នន័យ ដែលទាក់ទងនឹងមេរោគអេដស៍និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស ដើម្បីប្រើប្រាស់ព័ត៌មានជាយុទ្ធសាស្ត្រក្នុងការរៀបចំនូវគោលនយោបាយ គោលការណ៍ណែនាំ សេចក្តីប្រកាស និងសារាចរណែនាំ ។

ប្រការ ៣: អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស ។ ក្រុមការងារនេះត្រូវជួបប្រជុំគ្នាជាទៀងរាល់មួយត្រីមាសម្តង ។ កិច្ចប្រជុំរបស់ក្រុមការងារនឹងអាចប្រព្រឹត្តឡើងជាលក្ខណៈបន្ទាន់ប្រសិនបើក្នុងករណីដែលចាំបាច់ ។ កិច្ចប្រជុំនឹងធ្វើឡើងនៅក្នុងការិយាល័យរបស់សមាជិកក្រុមការងារណាមួយហើយអាចផ្លាស់ប្តូរវេនគ្នាបន្ទាប់ពីមានកិច្ចប្រជុំពីរបីដងរួចមក ហើយរបាយ-ការណ៍នៃកិច្ចប្រជុំនេះត្រូវផ្ញើរមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

ប្រការ ៤: ក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរសនេះ មានលេខាធិការដ្ឋានមួយនៅនាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ លេខាធិការដ្ឋាននេះមាន សមាសភាព និងតួនាទី ភារកិច្ចដូចខាងក្រោម :

**ក-សមាសភាពលេខាធិការដ្ឋាន**

| | | |
|---|---|---|
| - អនុប្រធាន នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | | ប្រធាន |
| - ប្រធានការិយាល័យ គ្រប់គ្រងកម្មវិធីបង្ការនាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ | | អនុប្រធាន |
| - តំណាង | អង្គការ UNAIDS | អនុប្រធាន |
| - តំណាង | អង្គការ UNESCO | សមាជិក |
| - តំណាង | អង្គការ សុខភាពគ្រួសារអន្តរជាតិ (FHI) | សមាជិក |
| - តំណាង | អង្គការ KHANA | សមាជិក |
| - តំណាង | អង្គការ PSI | សមាជិក |
| - តំណាង | អង្គការ PACT Cambodia | សមាជិក |
| - តំណាង | អង្គការ MHSS | សមាជិក |
| - តំណាង | បណ្តាញចតុមុខ (National MSM Network ) | សមាជិក |
| - តំណាង | អង្គការ ម៉ារីស្តូបអន្តរជាតិកម្ពុជា ( MSIC ) | សមាជិក |

## ៥- តួនាទី និងភារកិច្ចក្រុមលេខាធិការដ្ឋាន

- អនុវត្តការងារតាមសេចក្តីសំរេចចិត្តដែលធ្វើឡើងដោយអង្គប្រជុំរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស ។
- សំរបសំរួលក្នុងការស្វែងរកការគាំទ្រផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងការអនុវត្តន៍ ដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស ។
- ផ្តល់យោបល់ក្នុងការរៀបចំ ពិនិត្យឡើងវិញ កែសំរួល និងផ្តល់យោបល់គោលនយោបាយ គោលការណ៍ណែនាំ សេចក្តីប្រកាស និងសារាចរណែនាំ ដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស ។
- ផ្តល់យោបល់ក្នុងការរៀបចំ ពិនិត្យឡើងវិញ និងកែសំរួលផែនការយុទ្ធសាស្ត្រសំរាប់រយៈពេលវែង រយៈពេលខ្លី និងផែនការប្រតិបត្តិរបស់ក្រុមការងារបុរសស្រឡាញ់បុរស ។
- ពិគ្រោះយោបល់ក្នុងការធ្វើការប៉ាន់ប្រមាណ និងការស្រាវជ្រាវទាំងឡាយ ដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស ។
- សិក្សារកបញ្ហា ឬកង្វះខាត ដើម្បីកែលំអការអនុវត្តន៍កម្មវិធីបុរសស្រឡាញ់បុរសនៅក្នុងប្រទេស ។
- ចលនាប្រភពធនធានដែលអាចរកបានដើម្បីគាំទ្រសកម្មភាពលេខាធិការដ្ឋាន និងសកម្មភាពរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ សំរាប់ក្រុមបុរសស្រឡាញ់បុរស ។
- ប្រមូលផ្តុំផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នទាំងឡាយដែលធ្វើការទាក់ទងនឹងការងារក្រុមបុរសស្រឡាញ់បុរស ដើម្បីរក្សាស្ថិតិការងារ និងសំរបសំរួលស្របតាមផែនការយុទ្ធសាស្ត្រ ។
- ធ្វើកំណត់ហេតុកិច្ចប្រជុំទាំងឡាយរបស់ក្រុមការងារបច្ចេកទេស និងបែងចែកកំណត់ហេតុទៅសមាជិកទាំងអស់របស់ក្រុមការងារបច្ចេកទេស ។
- រក្សាកំណត់ហេតុនៃកិច្ចប្រជុំថ្នាក់ជាតិ និងថ្នាក់តំបន់ដែលពាក់ព័ន្ធនឹងការងារក្រុមបុរសស្រឡាញ់បុរស ។
- ផ្តល់ព័ត៌មានទាន់ពេលដល់សមាជិកក្រុមការងារបច្ចេកទេសអំពីបញ្ហា និងអន្តរាគមន៍ទាំងឡាយពាក់ព័ន្ធនឹងក្រុមបុរសស្រឡាញ់បុរសនៅក្នុងប្រទេស និងក្នុងតំបន់ ។
- រក្សាមុខងារទំនាក់ទំនងរវាងក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងភាគីពាក់ព័ន្ធឯទៀត និងចែកចាយកំណត់ហេតុអង្គប្រជុំ និងរាយការពីដំណើរការការងាររបស់លេខាធិការដ្ឋាន ។
- ស្នើឡើងនូវរបៀបវារៈសំរាប់កិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស ។
- រៀបចំកម្មវិធីចុះតាមដានការអនុវត្តសកម្មភាពការងាររបស់អង្គការក្រៅរដ្ឋាភិបាលជាដៃគូរ ។

- រៀបចំកម្មវិធីចុះសួរសុខទុក្ខបណ្តាញក្រុមបុរសស្រឡាញ់បុរសនៅថ្នាក់ខេត្ត-ក្រុង ។
- លេខាធិការដ្ឋានត្រូវមានកិច្ចប្រជុំក្នុង១ខែម្តង ។

**ប្រការ ៥:** សមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់បុរសស្រឡាញ់បុរសត្រូវគោរពតាមសេចក្តីសំរេចចិត្តរួមរបស់ក្រុមការងារដែលធ្វើឡើងក្នុងការប្រជុំទាំងឡាយនៃក្រុមការងារ ។

**ប្រការ ៦:** និរាករណ៍សេចក្តីសំរេចលេខ ១៩៤ អ.ប.ជ.ប.អ/ធស ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០៧ ។

**ប្រការ ៧:** សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.ប្រធាន

អនុប្រធាន

វេជ្ជ. ឆា ផលា

**<u>ចម្លងជូន :</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការអេដស៍ក្រសួងពាក់ព័ន្ធ
- គណៈកម្មាធិការអេដស៍ខេត្ត-ក្រុងពាក់ព័ន្ធ
- អង្គការជាតិ-អន្តរជាតិ និងដៃគូពាក់ព័ន្ធ
- ឯកសារ